CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 10 ខែមិថុនា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុងឡុងប៊ិច នឹងអនុលោមតាម គោលការណ៍ណែនាំ អំពីការពាក់ម៉ាស់ របស់នាយកដ្ឋានសុខភាពសាធារណៈ កាលីហ្វ័រញ៉ា ។

ឡុងប៊ិច, CA - នៅថ្ងៃទី 9 ខែមិថុនា ឆ្នាំ 2021 នាយកដ្ឋានសុខភាពសាធារណៈ កាលីហ្វ័រញ៉ា (CDPH) បានដាក់ចេញ គោលការណ៍ណែនាំថ្មី ស្តីពីការប្រើប្រាស់ម៉ាស់ សម្រាប់បុគ្គលម្នាក់ៗ ដើម្បីបង្ការការឆ្លងរីករាល COVID-19 ។ គោលការណ៍ណែនាំ ដែលបានធ្វើបច្ចុប្បន្នភាពរួចនេះ អនុលោមតាមគោលការណ៍ណែនាំស្តីពីការពាក់ម៉ាស់ ដែលដាក់ចេញដោយ មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ និងចូលជាធរមាន នៅថ្ងៃទី 15 ខែមិថុនា ឆ្នាំ 2021 ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) បានបញ្ជាក់ថា «ជាការសំខាន់ សម្រាប់ពលករ និងធុរកិច្ចតូចៗ ដែលយើងគោរពតាមរដ្ឋ ចំពោះវិធានពាក់ម៉ាស់នេះ ។» «យើងខ្ញុំគ្មានផែនការ អនុវត្តវិធាន តឹងតែងជាង វិធានដែលមានកំណត់រួច ដោយ CDC និងនាយកដ្ឋានសុខភាពសាធារណៈ កាលីហ្វ័រញ៉ា នោះទេ ។»

ក្រោមគោលការណ៍ណែនាំ CDPH ថ្មី **អ្នកបានចាក់វ៉ាក់សាំងគ្រប់ដូសរួច** មិនត្រូវបានតម្រូវឱ្យ ពាក់របាំងមុខ នៅក្នុងបរិបទមួយចំនួន ដូចជា កន្លែងថែទាំសុខភាព មធ្យោបាយធ្វើដំណើរសាធារណៈ រួមទាំង តែមិនកំណត់ត្រឹម អាកាសយានយន្ត រថយន្តក្រុង រថយន្តតាក់ស៊ី និង រថយន្តជិះរួមគ្នា ព្រមទាំងសាលា K-12, កន្លែងថែទាំកុមារ និងកន្លែងយុវជនផ្សេងៗ ទៀត, និង បរិបទទីលំនៅសមូហភាព មួយចំនួន (ដូចជា ទីជម្រកជនគ្មានទីលំនៅ និងសម្បទាពន្ធនាគារ) ។ សាលាក្រុងឡុងប៊ិច នឹងអនុលោមតាម រដ្ឋ ចំពោះគោលការណ៍ណែនាំ អំពីការពាក់ម៉ាស់ ។

ការពាក់របាំងមុខ នៅតែតម្រូវឱ្យអនុវត្ត សម្រាប់**អ្នកដែលមិនទាន់បានចាក់វ៉ាក់សាំង** នៅក្នុងបរិបទអគារសាធារណៈ និងអគារធុរកិច្ច រួមទាំង តែមិនកម្រិតត្រឹម ភោជនីយដ្ឋាន សំណង់ផ្សារលក់រាយ និងមជ្ឈមណ្ឌលកំសាន្ត លក្ខណៈគ្រួសារ ។

CDPH ក៏បានកំណត់ គោលការណ៍ណែនាំ សម្រាប់ព្រឹត្តិការណ៍ធំៗ មានលក្ខណៈ ជាព្រឹត្តិការណ៍ រៀបចំឡើងនៅក្នុងអគារ ដែលមានអ្នកចូលរួម ច្រើនជាង 5,000 នាក់ ឬ ព្រឹត្តិការណ៍នៅទីបើកចំហរ ដែលមានអ្នកចូលរួម ច្រើនជាង 10,000 នាក់ ផងដែរ ។

CITY OF LONG BEACH

# PRESS RELEASE

ព្រឹត្តិការណ៍ធំៗ នៅក្នុងអគារ ដូចជា កិច្ចប្រជុំ, សន្និសីត, កម្មវិធីពិពណ៌, ព្រឹត្តិការណ៍កីឡា និងកម្មវិធីសម្តែងធំៗ ត្រូវគោរពតាម គោលការណ៍ណែនាំ ដូចតទៅនេះ ជាបន្ថែមលើអនុសាសន៍សុខភាពសាធារណៈទូទៅ ៖

- អ្នកចូលរួមទាំងអស់ត្រូវ មានការផ្ទៀងផ្ទាត់ ពីស្ថានភាពចាក់វ៉ាក់សាំង ឱ្យបានគ្រប់ដូស ឬ ត្រូវមាន លទ្ធផលតេស្តអវិជ្ជមាន មុនអាចចូលរួមបាន ។
- ព័ត៌មាននេះ នឹងមានរំលេចជូន យ៉ាងច្បាស់ នៅក្នុងគ្រប់ការប្រាស្រ័យទាក់ទងទាំងអស់ រួមទាំង ប្រព័ន្ធកក់ និងទិញសំបុត្រ ដើម្បីធានាថា ភ្ញៀវអាចដឹងពី លក្ខខណ្ឌតម្រូវឱ្យមាន ការចាក់វ៉ាក់សាំង ឱ្យបានគ្រប់ដូស និងការធ្វើតេស្ត (រួមទាំង របៀបផ្ទៀងផ្ទាត់ ដែលអាចទទួលយកបាន) ។

ព្រឹត្តិការណ៍ធំៗ នៅទីបើកចំហរ ដូចជា កម្មវិធីប្រគំតន្ត្រី ឬ ពិធីបុណ្យចំណីអាហារ, កម្មវិធីពិពណ៌រថយន្ត, កម្មវិធីប្រកួតធំៗ, កម្មវិធីរត់ម៉ារ៉ាតុង, កម្មវិធីដង្ហែរក្បួន, ព្រឹត្តិការណ៍កីឡា និងកម្មវិធីសម្តែងធំៗ ត្រូវគោរពតាម គោលការណ៍ណែនាំ ដូចតទៅនេះ ជាបន្ថែមលើអនុសាសន៍សុខភាពសាធារណៈទូទៅ ៖

- ការផ្ទៀងផ្ទាត់ លើការចាក់វ៉ាក់សាំង ឱ្យបានគ្រប់ដូស ឬ លទ្ធផលតេស្ត អវិជ្ជមាន មុនពេលចូលរួម ត្រូវបានណែនាំឱ្យអនុវត្ត យ៉ាងមុតមាំ សម្រាប់គ្រប់អ្នកចូលរួមទាំងអស់ ។
- អ្នកចូលរួម ដែលមិនបានផ្ទៀងផ្ទាត់ស្ថានភាពចាក់វ៉ាក់សាំង គួរត្រូវបានស្នើសុំឱ្យពាក់របាំងមុខ ។
- ព័ត៌មាននេះ នឹងមានរំលេចជូន យ៉ាងច្បាស់ នៅក្នុងគ្រប់ការប្រាស្រ័យទាក់ទងទាំងអស់ រួមទាំង ប្រព័ន្ធកក់ និងទិញសំបុត្រ ដើម្បីធានាថា ភ្ញៀវអាចដឹងថា រដ្ឋធ្វើការណែនាំ យ៉ាងមុតមាំថា ពួកគេត្រូវចាក់វ៉ាក់សាំង ឱ្យបានគ្រប់ដូស, ទទួលបានលទ្ធផលតេស្ត COVID-19 អវិជ្ជមាន មុនពេលចូលរួមព្រឹត្តិការណ៍ បើមិនដូច្នោះទេ ត្រូវពាក់របាំងមុខ ។

គោលការណ៍ណែនាំ ស្តីពីករណីអាសន្ន របស់នាយកដ្ឋានសុវត្ថិភាព និងសុខភាពការងារ កាលីហ្វ័រញ៉ា (Cal/OSHA) ដែលដាក់ឱ្យអនុវត្ត កាលពីខែវិច្ឆិកា នៅបន្តរមានសុពលភាព ។ គោលការណ៍ណែនាំ របស់ក្រុមប្រឹក្សាសុវត្ថិភាព និងបទដ្ឋានការងារ កាលីហ្វ័រញ៉ា ដែលដាក់ឱ្យអនុវត្តនៅថ្ងៃទី 3 ខែមិថុនា ឆ្នាំ 2021 ត្រូវបានដកលែងឱ្យអនុវត្ត នៅកិច្ចប្រជុំ កាលពីថ្ងៃទី 9 ខែមិថុនា ដោយត្រឡប់ទៅអនុវត្ត លក្ខខណ្ឌតម្រូវ មានកំណត់កាលពីខែវិច្ឆិកា ឆ្នាំ 2020 ដែលឱ្យពាក់ម៉ាស់ រក្សាគម្លាត ធ្វើតេស្ត និងសម្អាតអនាម័យវិញ ។ និយោជិត នៅតែត្រូវពាក់របាំងមុខ និងរក្សាគម្លាត នៅពេលបំពេញការងារ ទោះបីជាបានចាក់វ៉ាក់សាំងហើយក្តី ។ ក្រុមប្រឹក្សាសុវត្ថិភាព និងបទដ្ឋានការងារ កាលីហ្វ័រញ៉ា ទន្ទឹងចាំ គោលការណ៍ណែនាំ ដែលបានធ្វើបច្ចុប្បន្នភាពរួច ដើម្បីយកមកធ្វើបទបង្ហាញ សម្រាប់បោះឆ្នោត នៅកិច្ចប្រជុំ នាថ្ងៃទី 17 ខែមិថុនា របស់ខ្លួន ។ ការកែសម្រួលណាមួយ នឹងចូលជាធរមាន នៅថ្ងៃទី 28 ខែមិថុនា ។ សាលាក្រុងរំពឹងថា នឹងអនុវត្តតាម គោលការណ៍ណែនាំ Cal/OSHA នៅពេលគោលការណ៍ណែនាំនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពរួច ។

សេចក្តីណែនាំ អំពីការពាក់ម៉ាស់ របស់រដ្ឋ និងទីក្រុង ដែលមានស្រាប់ នឹងនៅតែបន្តអនុវត្ត រហូតដល់ថ្ងៃទី 15 ខែមិថុនា ។ បទបញ្ជារដ្ឋ ដែលផ្លាស់ប្តូរ គោលការណ៍ណែនាំ ដែលមានស្រាប់ ត្រូវបានរំពឹងថា រដ្ឋនឹងដាក់ចេញ នៅមុនថ្ងៃទី 15 ខែមិថុនា ដែលសាលាក្រុងនឹងអនុវត្តតាម ។

# # #